# ស្ថានបេសកកម្មអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជា
# ប្រចាំអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានា នៅហ្សឺណែវ

**បទអន្តរាគមន៍**
**របស់ឯកអគ្គរាជទូត និងជាតំណាងអចិន្ត្រៃយ៍កម្ពុជា អាន សុខខឿន**
**នាសម័យប្រជុំលើកទី៤៦ នៃក្រុមប្រឹក្សាសិទ្ធិមនុស្ស**
**ក្នុងកិច្ចពិភាក្សាទូទៅលើរបៀបវារៈទី១០ ស្តីពី កិច្ចសហប្រតិបត្តិការបច្ចេកទេស**
**"សិទ្ធិឆ្លើយតបទៅនឹងគណៈប្រតិភូហ្សាំងឡង់"**
**ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ ទីក្រុងហ្សឺណែវ**
**[រយៈពេលថ្លែង៖ ៣ នាទី]**

លោកជំទាវប្រធានក្រុមប្រឹក្សាសិទ្ធិមនុស្ស!

1. គណៈប្រតិភូយើងខ្ញុំសូមប្រើប្រាស់សិទ្ធិឆ្លើយតបទៅនឹងសេចក្តីថ្លែងការណ៍របស់គណៈប្រតិភូហ្សាំងឡង់។

2. យើងខ្ញុំកត់សម្គាល់ដោយការខកចិត្តយ៉ាងខ្លាំង ចំពោះគណៈប្រតិភូខាងលើដែលបានបដិសេធ មិនប្រកាន់យកវិធីសាស្ត្រប្រកបដោយភាពសត្យានុម័ត មិនជ្រើសរើសតែមួយជ្រុង និងមិនធ្វើនយោបាយូបនីយកម្ម នៅពេលវាយតម្លៃស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។ ក្នុងន័យនេះ យើងខ្ញុំសូមផ្តល់ជូនអង្គប្រជុំនូវតថភាពមួយចំនួន ដូចតទៅ៖
   - ទី១៖ ការអំពាវនាវឱ្យកម្ពុជាសហការជាមួយការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សបានបង្ហាញឱ្យឃើញយ៉ាងច្បាស់នូវការមិនអើពើរបស់ហ្សាំងឡង់ចំពោះការពិតនៅកម្ពុជា។ វត្តមានជិតបីទសវត្សរ៍នៃការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស ប្រចាំកម្ពុជា ចាប់តាំងពីឆ្នាំ ១៩៩៣ មក ដែលបច្ចុប្បន្ននេះ ក្លាយជាការិយាល័យវ៉ែចំណាស់ជាងគេបំផុតនៅលើពិភពលោក គឺជាសក្ខីភាពមួយឆ្លុះបញ្ចាំងអំពីកិច្ចសហប្រតិបត្តិការដោយបើកចំហ និងស្ថាបនារបស់កម្ពុជា ជាមួយការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ។ កាលពីខែធ្នូ កន្លងទៅ រាជរដ្ឋាភិបាលកម្ពុជាបានបន្តសុពលភាពអនុស្សរណៈយោគយល់ជាមួយការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ដែលប្រការនេះស្តែងឱ្យឃើញយ៉ាងច្បាស់នូវការប្តេជ្ញាចិត្តឥតងាករេ របស់កម្ពុជា ក្នុងការលើកកម្ពស់សិទ្ធិមនុស្សគ្រប់ប្រភេទ តាមរយៈកម្មវិធីកិច្ចសហប្រតិបត្តិការបច្ចេកទេស។

   - ទី២៖ ជារឿងគួរឱ្យអស់សំណើចដែលហ្សាំងឡង់ទើបប្រកាសបិទប្រទេស និងដាក់ប្រទេសក្នុងភាពអាសន្ន ធ្វើឱ្យមានការរឹតត្បិតសេរីភាពមូលដ្ឋានរបស់ប្រជាជនខ្លួន នាពេលថ្មីៗនេះ បែរជាមកទាមទារឱ្យកម្ពុជា គោរពសិទ្ធិពលរដ្ឋនិងនយោបាយ ជាងសិទ្ធិដទៃទៀត។ ទង្វើនេះគឺងាកចេញពីគន្លងនៃវិធីសាស្ត្ររបស់ អគ្គលេខាធិការអង្គការសហប្រជាជាតិ

ឯកឧត្តម អាន់តូនីញ៉ូ គូតេរ៉េស ដែលធ្លាប់បានគូសបញ្ជាក់ក្នុងក្រុមប្រឹក្សាសិទ្ធិមនុស្សនេះ ថា "សិទ្ធិមនុស្សមិនត្រូវក្លាយជាមធ្យោបាយ ដើម្បីអនុវត្តស្តង់ដារពីរ ឬជាឧបករណ៍ ដើម្បីសម្រេចរបៀបវារៈលាក់ពុតណាមួយឡើយ"។ លើសពីនេះ សេចក្តីសម្រេចចិត្តនានារបស់អង្គការសហប្រជាជាតិក៏បានបញ្ជាក់ដែរថា សិទ្ធិមនុស្សទាំងអស់ រួមមានសិទ្ធិពលរដ្ឋ នយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌ ព្រមទាំងសិទ្ធិទទួលបានការអភិវឌ្ឍ ត្រូវបានចាត់ទុកថា មានតម្លៃស្មើគ្នា ឈរលើជំហរតែមួយ និងមានសារៈសំខាន់ដូចៗគ្នា។

- ទី៣៖ ច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃមេរោគកូវីដ-១៩ ដែលត្រូវបានអនុម័តនាពេលថ្មីៗនេះ ដោយសភាទាំងពីរថ្នាក់របស់កម្ពុជា ប្រកាន់ខ្ជាប់នូវគោលការណ៍នីត្យានុកូលភាព ភាពចាំបាច់ និងសមាមាត្រភាព។ ច្បាប់នេះពុំមានគោលបំណងដាក់ទោសទណ្ឌលើបុគ្គលណាម្នាក់នោះទេ ផ្ទុយទៅវិញច្បាប់នេះមានគោលបំណងការពារអាយុជីវិត និងលើកទឹកចិត្តពលរដ្ឋគ្រប់រូបឱ្យចូលរួមប្រកបដោយការទទួលខុសត្រូវខ្ពស់ក្នុងកិច្ចប្រឹងប្រែងធានាសុវត្ថិភាពសុខភាពសាធារណៈ និងអាយុជីវិតដ៏មានតម្លៃរបស់ពលរដ្ឋ។ ដូចក្នុងបណ្តាប្រទេសលោកខាងលិចដែរ វិធានការទាំងនោះនឹងត្រូវអនុវត្តចំពោះតែបុគ្គលទាំងឡាយណាដែលបំពានច្បាប់ បង្កឱ្យមានការចម្លងជំងឺរាតត្បាតចូលក្នុងសហគមន៍ប៉ុណ្ណោះ ដោយផ្អែកលើប្រភេទបទល្មើស និងចេតនាក្នុងការប្រព្រឹត្ត ។

- ទី៤៖ មានតែពលរដ្ឋកម្ពុជាប៉ុណ្ណោះ ដែលមានសិទ្ធិខ្ពស់បំផុតក្នុងការវាយតម្លៃពីស្ថានភាពលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស នៅកម្ពុជា។ សិទ្ធិអំណាចរបស់ពលរដ្ឋកម្ពុជាត្រូវបានឆ្លុះបញ្ចាំងតាមរយៈលទ្ធផលនៃការបោះឆ្នោត ដែលបុគ្គលគ្រប់រូបត្រូវតែគោរពតាម។ អគ្គលេខាធិការ អង្គការសហប្រជាជាតិ ឯកឧត្តម អាន់តូនីញ៉ូ គូតេរ៉េស បានពន្យល់ថា ជោគជ័យនៃវិញ្ញាសារខាងលើត្រូវវាស់ស្ទង់ ដោយប្រើប្រាស់មាត្រដ្ឋាននៃភាពប្រសើរឡើងក្នុងជីវភាពរបស់ពលរដ្ឋ មិនមែនផ្អែកលើការបញ្ចេញអារម្មណ៍វិនិច្ឆ័យឡើយ។

3. ជាចុងបញ្ចប់ របៀបវារៈទី១០នេះគួរដើរតួនាទីស្នូលក្នុងការលើកកម្ពស់កិច្ចពិភាក្សាប្រកបដោយការគោរព ស្តីពី ឧត្តមានុវត្តន៍សកលពាក់ព័ន្ធនឹងកិច្ចសប្រតិបត្តិការបច្ចេកទេស។ ការបំពានរបៀបវារៈនេះ ក្នុងគោលបំណងស្វែងរកពិន្ទុនយោបាយ គួរតែត្រូវជៀសវាង ប្រសិនបើយើងទាំងអស់គ្នាប្រាថ្នាចង់រក្សាការពារនូវសុចរិតភាពនិងភាពអាចជឿទុកចិត្តបានខ្ពស់បំផុតរបស់ស្ថាប័នសិទ្ធិមនុស្សមួយនេះ។

សូមអរគុណ!